**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ៥,៥ លានដុល្លារនៃការវិនិយោគលើគម្រោងកាត់ដេរថ្មី នឹងបង្កើតការងារចំនួន ១ ២០០ កន្លែង
- អូស្ត្រាលី គាំទ្រការអភិវឌ្ឍពូជស្រូវក្រអូបថ្មីនៅកម្ពុជា
- វិបត្តិទីផ្សារមៀនប៉ៃលិននៅខេត្តជាប់ព្រំដែនកម្ពុជា ថៃ ត្រូវបានសង្គ្រោះដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា
- ទឹកប្រាក់នាំចេញ-នាំចូលរបស់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ កើន ៤៥%
- កំណើនពាណិជ្ជកម្មរបស់វៀតណាម នាពាក់កណ្ដាលខែចុងក្រោយ នៃខែមិថុនាឆ្នាំ២០២១
- កំណើននាំចេញផលិតផលមិនមែនប្រេង របស់សិង្ហបុរី ទៅទីផ្សារធំៗទាំង១០ ក្នុងខែមិថុនា ឆ្នាំ២០២១
- សេដ្ឋកិច្ចរបស់ថៃ កើនឡើងលើសពីការព្យាករណ៍ទុកនៅក្នុងត្រីមាសទី២ ឆ្នាំ២០២១
- ប្រធានាធិបតីឥណ្ឌូនេស៊ី ជំរុញឱ្យមានការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ
- ពាណិជ្ជកម្មកម្ពុជា-ជប៉ុនកើនឡើងនៅឆមាសទី១ ឆ្នាំ ២០២១ ដល់ ១,១ ពាន់លានដុល្លារ
- កម្ពុជា និងម៉ាឡេស៊ី មានប្រព័ន្ធទូទាត់ហិរញ្ញវត្ថុឌីជីថលឆ្លងដែន តាមរយៈកម្មវិធីទូទាត់ «បាគង»
- និយោជកនៅចក្រភពអង់គ្លេស មានផែនការយ៉ាងមុតមាំក្នុងការជួលបុគ្គលិក ធៀបនឹងរយៈពេលជាង ៨ឆ្នាំ
- រដ្ឋបាលលោក បៃដិន បញ្ជាក់ពីការបង្កើនបណ្ណសម្រាប់ទិញអាហារក្នុងកំណត់ត្រាឯកត្តកម្ម
- សេដ្ឋកិច្ចរុស្ស៊ីងើបឡើងវិញក្នុងត្រីមាសទី ២ ដោយកត្តាជំរុញសំខាន់ ៣
- ការប្រើប្រាស់មាសនៅចិន កើនឡើងជាង៦៩% ក្នុងឆមាសទី១ឆ្នាំនេះ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី	អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា	អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី	ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ	អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា   សប្តាហ៍ទី៣ ខែសីហា ឆ្នាំ២០២១   លេខ ៖ ៨១

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ៥,៥ លានដុល្លារនៃការវិនិយោគលើគម្រោងកាត់ដេរថ្មី នឹងបង្កើតការងារចំនួន ១ ២០០ កន្លែង



*ប្រភពរូបថត៖ Khem Sovannara, Khmer Times ២០២១*

គម្រោងវិនិយោគថ្មី ចំនួន ២ ដែលមានតម្លៃសរុប ៥,៥ លានដុល្លារ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។

គម្រោងនេះ រួមមាន ក្រុមហ៊ុន Collaboration Packaging Material Products Co Ltd កំពុងសាងសង់រោងចក្រមួយនៅស្រុកអង្គស្នួលខេត្តកណ្តាល ដើម្បីផលិតគ្រឿងបន្លាស់សម្រាប់កាបូប និងស្បែកជើង និងក្រុមហ៊ុន Chasefire Outdoors (Cambodia) Co Ltd ដែលនឹងបង្កើតរោងចក្រមួយនៅក្នុងស្រុកសំរោង ខេត្តតាកែវ ដើម្បីផលិតសំលៀកបំពាក់សុវត្ថិភាព កាបូប និងសម្ភារៈបោះជំរុំ។ គម្រោងទាំងពីរនេះ ត្រូវបានគេរំពឹងថានឹងបង្កើតការងារជាង ១ ២០០ កន្លែងសម្រាប់ប្រជាជនក្នុងតំបន់។

ជាមួយគ្នានេះផងដែរ នាពេលថ្មីៗនេះ CDCបានអនុម័តគម្រោងចំនួន ១០ ដែលភាគច្រើនជាគម្រោងសម្លៀក-បំពាក់ កាបូបធ្វើដំណើរ និងស្បែកជើង។ គម្រោងទាំងនោះ មានតម្លៃជិត ៨០ លានដុល្លារ ហើយត្រូវបានរំពឹងថានឹងបង្កើតការងារប្រហែល ១១ ៥០០កន្លែង ខណៈពេលដែល កាលពីឆ្នាំមុនរោងចក្រចំនួន ១០១ ត្រូវបានបិទទ្វា នៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើនជារោងចក្រក្នុងវិស័យកាត់ដេរ នេះបើយោងតាមក្រសួងឧស្សាហកម្ម ។ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១*

### អូស្ត្រាលី គាំទ្រការអភិវឌ្ឍពូជស្រូវក្រអូបថ្មីនៅកម្ពុជា



*ប្រភព៖ ស្មើកម្ពុជា ២០២១*

ដោយមានការគាំទ្រពីអូស្ត្រាលី វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងសហព័ន្ធស្រូវអង្ករកម្ពុជា បានបង្កើតអង្ករក្រអូបប្រភេទថ្មី ដែលអាចដាំដុះបានគ្រប់ពេលវេលា អោយតែមានទឹក។ ពូជស្រូវថ្មីនេះមានគុណភាពខ្ពស់ និងមានតម្លៃខ្ពស់ ហើយកំពុងពេញនិយមនៅលើទីផ្សារអន្តរជាតិ។ ពូជស្រូវថ្មីនេះ មានឈ្មោះថា ផ្កាមាលតី ដែលត្រូវបានស្រាវជ្រាវ រកឃើញកាលពីឆ្នាំ២០១៨ និងកំពុងផ្សព្វផ្សាយ ឱ្យកសិករផលិត។

ស្រូវក្រអូបកំពុងតែដើរតួរយ៉ាងសំខាន់នៅក្នុងឧស្សាហកម្ម ស្រូវអង្ករនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ ពូជស្រូវក្រអូបប្រណីតប្រពៃណីស្ទើរតែទាំងអស់ វេទរសទៅនឹងពន្លឺ (ប្រកាន់រដូវ) ដែលកសិករដាំបានតែម្តងក្នុងមួយឆ្នាំ គឺនៅរដូវវស្សា។ ដូច្នេះ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានអភិវឌ្ឍន៍ស្រទ្បាយស្រូវក្រអូបដែលអវេទរសទៅនឹងពន្លឺ(មិនប្រកាន់រដូវ)ដោយបង្កាត់រវាងពូជស្រូវផ្ការំដួល(មេ) និងស្រទ្បាយ CNi9024 (បា) ដែលមានប្រភពមកពីប្រទេសចិន និងអវេទរសទៅនឹងពន្លឺ (មិនប្រកាន់រដូវ)។ តាមរយៈការជ្រើសរើសជាបន្តបន្ទាប់ ស្រទ្បាយចំនួន១០០ បានដាំ និងជ្រើសរើសក្នុងរដូវប្រាំង និងរដូវវស្សា។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ រស្មីកម្ពុជា ចេញផ្សាយនាថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០២១។*

## វិបត្តិទីផ្សារមៀនប៉ៃលិននៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា ថៃ ត្រូវបានជួយសង្គ្រោះដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា



*ប្រភព ៖ កោះសន្តិភាព ២០២១*

ចាប់ពីដើមខែសីហាមក ការប្រមូលផលផ្លែមៀនប៉ៃលិនបានចាប់ផ្តើម ប៉ុន្តែមិនអាចនាំចេញទៅកាន់រោងចក្ររបស់ចិនមួយនៅក្នុងទឹកដីថៃ ។

កន្លងមកមានវិនិយោគិនចិន បានដាក់ទុនវិនិយោគរោងចក្រកែច្នៃផ្លែមៀននៅទឹកដីកម្ពុជារួចរាល់ហើយ ក្នុងដើមទុន ៥លានដុល្លារអាមេរិក ប៉ុន្តែរោងចក្រនេះមិនអាចដំណើរការបាន ព្រោះតែរបាំងភូតគាមអនាម័យ ដូច្នេះវិនិយោគគិនចិន ដំណើរការរោងចក្ររបស់ខ្លួន តែនៅក្នុងប្រទេសថៃ ព្រោះថៃ មានសិទ្ធិនាំចេញផ្លែមៀន។

សមាជិកក្រុមប្រឹក្សាភិបាលនៃសហគមន៍ មៀនប៉ៃលិន បានសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា ពន្លឿនការចរចាភូតគាមអនាម័យចំពោះផ្លែមៀននេះ ជាមួយភាគីចិនឱ្យបានឆាប់ ដើម្បីបើកច្រកនាំចេញទៅដោយផ្ទាល់ មិនចាំបាច់ឆ្លងប្រទេសទី៣ទៀត ដែលនាំឱ្យកសិករកម្ពុជាពិបាកដឹកទៅកាន់រោងចក្រចិននៅលើទឹកដីថៃ។

ផលិតផលមៀនប៉ៃលិន ដែលអាចខូចខាតក្នុងឆ្នាំនេះ មានចំនួនប្រមាណ ៣០លាន ទៅ៥០លានដុល្លារអាមេរិក (គិតតម្លៃទីផ្សារពី៣ ០០០រៀលទៅ៤ ០០០រៀល ក្នុងមួយគីឡូក្រាម)។

ទីផ្សារមៀនក្នុងស្រុក មានទំហំតិចបំផុត ដោយមានតម្រូវការសម្រាប់តែថ្ងៃសីលប៉ុណ្ណោះ ដូច្នេះ កសិករត្រូវពឹងលើការនាំចេញ តែបើសិនជាការបិទព្រំដែននៅបន្តកសិករគ្មានអ្វីក្រៅពីចាក់ទិន្នផលចោលឡើយ។

ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តប៉ៃលិន បានលើកឡើងថា ឆ្នាំ២០២១នេះ ផ្ទៃដីដាំដុះផ្លែមៀន ឬតាង៉ែន មានទំហំ៤ ៦៥០ហិចតា កើនឡើង ៥០ហិចតា បើធៀបនឹងឆ្នាំមុនដែលមាន ៤ ៦០០ ហិចតា។

ស្របពេលដែលវិបត្តិទីផ្សារផ្លែមៀន ឬតាង៉ែននៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា ថៃ ពិសេសខេត្តប៉ៃលិន និងបាត់ដំបង ដែលជួបប្រទះនូវបញ្ហាក្នុងការនាំចេញទៅលក់នៅក្រៅប្រទេស ដោយសារការឆ្លងរីករាលដាលជំងឺកូវី១៩នោះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងទឹកចិត្ត

គាំទ្រផលិតផលក្នុងស្រុក បានដោះស្រាយការលំបាកចំពោះមុខនេះ គឺទទួលទិញពីប្រជាកសិករយកទៅផ្គត់ផ្គង់ទីផ្សារក្នុងស្រុក។

ជាមួយគ្នាផងដែរ សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា ក៏បានសម្រេចទិញផ្លែមៀនចំនួន២១តោនដែរ ដើម្បីចែកជូនក្រុមគ្រូពេទ្យ និងអ្នកជំងឺកូវីដ១៩ ដែលកំពុងសម្រាកព្យាបាលតាមមន្ទីរពេទ្យមួយចំនួន នៅរាជធានីភ្នំពេញ ដូចខាងក្រោម ៖

ទី១៖ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ដេចតេជោ(TYDA)៦តោន
ទី២៖ មន្ទីរពេទ្យរុស្សី ចំនួន៥តោន
ទី៣៖ មន្ទីរពេទ្យជ័យជំនះ ចំនួន៥តោន
ទី៤៖ ស្តាតអូឡាំពិក កន្លែងព្យាបាលជំងឺកូវីដ ៥តោន។

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់ថា ពេលនេះមន្ត្រីជាន់ខ្ពស់កំពុងចរចាអំពីភូតគាមអនាម័យជាមួយភាគីចិនរួចហើយ ដើម្បីជំរុញការនាំចេញផ្លែឈើមួយនេះទៅកាន់ប្រទេសចិនបានឆាប់ ខណៈផ្លែឈើមួយចំនួនដូចជាផ្លែចេកអំបូងលឿង និងផ្លែស្វាយស្រស់ បានទៅកាន់ទីផ្សារចិនរួចហើយ៕*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ កោះសន្តិភាព ចេញផ្សាយនាថ្ងៃទី១៣ ខែ សីហា ឆ្នាំ ២០២១ CNC ចេញផ្សាយនាថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០២១ និង FressNewsចេញផ្សាយនាថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០២១។*

## ទឹកប្រាក់នាំចេញ-នាំចូលរបស់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ(SSEZ) កើន ៤៥%



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១*

ក្នុងរយៈពេល ៧ ខែដើមឆ្នាំ ២០២១ បរិមាណនាំចេញ និងនាំចូលទំនិញរបស់ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ(SSEZ)នៅបន្តកើនប្រមាណជិត៤៥%។ គិតចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២១ SSEZ ទទួលបានបរិមាណនាំចូល និងនាំចេញសរុប ១ ១៨៥ លានដុល្លារកើនឡើង៤៤,៥១% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០២០។

ប្រធានសមាគម ដឹកជញ្ជូនកម្ពុជា(CLA) បានប្រាប់ថា សកម្មភាពដឹកជញ្ជូននៅកម្ពុជានៅតែបន្តរងផលប៉ះពាល់យ៉ាងខ្លាំងចាប់តាំងពីមានជំងឺកូវីដ១៩ ប៉ុន្តែសកម្មភាពដឹកជញ្ជូនទំនិញផ្នែកខ្លះមានការរីកចម្រើន ដូចជានៅតំបន់សេដ្ឋកិច្ចពិសេសមួយចំនួន មានការកើនឡើងខ្ពស់ហួសពីការរំពឹងទុក ហើយកន្លែងខ្លះក៏ធ្លាក់ចុះយ៉ាងគំហុក។ តំបន់ដែលសកម្មភាពនាំចេញ និងនាំចូលទំនិញ ហក់ឡើងខ្ពស់គឺដោយសារមានតម្រូវការទីផ្សារ ដូចជា ទំនិញកសិកម្មក្រៅពីអង្ករមានការនាំចេញហក់ឡើង និងគ្រឿងបង្គុំអគ្គិសនី អេឡិចត្រូនិក កង់ ក៏មានការកើនឡើងផងដែរ។

អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា ក៏បានឱ្យដឹងដែរថា រហូតមកដល់ពេលនេះការនាំចេញរបស់កម្ពុជាមិនមានការថមថយទេ បើទោះជាមានវិបត្តិកូវីដ-១៩ក៏ដោយ។ ជាមួយគ្នានេះកម្ពុជាក៏កំពុងធ្វើពិពិធកម្មទំនិញនាំចេញរបស់ខ្លួនឱ្យកាន់តែមានភាពសម្បូរបែបទៅកាន់ទីផ្សារអន្តរជាតិផងដែរ។ ទន្ទឹមនឹងកំណើននាំចេញ ការនាំចូលវត្ថុធាតុដើមសម្រាប់កែច្នៃ ក៏នឹងកើនឡើងទៅតាមនេះដែរ ដែលនេះជាមូលហេតុនាំឱ្យការនាំចូលមានកំណើន។

SSEZ ត្រូវបានវិនិយោគរួមគ្នាដោយវិនិយោគិនខ្មែរ និងវិនិយោគិនចិន ដោយប្តេជ្ញាបង្កើតវេទិកាវិនិយោគពហុ-ជាតិសាសន៍សម្រាប់ក្រុមហ៊ុននៅជុំវិញពិភពលោក។ នៅដំណាក់កាលដំបូងតំបន់សេដ្ឋកិច្ចពិសេស SSEZ នឹងផ្តោតលើវិស័យវាយនភណ្ឌកាត់ដេរ កាបូប ស្បែកជើង ផលិតផលពីឈើជាដើម ដែលជាឧស្សាហកម្មចម្បងសម្រាប់ការអភិវឌ្ឍ។ ចំណែកនៅដំណាក់កាលទី២ SSEZ នឹងផ្តោតលើការទាញយកប្រយោជន៍ពីកំពង់ផែ និងផ្តោតលើការណែនាំអំពីគ្រឿងម៉ាស៊ីន សម្ភារសំណង់ គ្រឿងសង្ហារិមគេហដ្ឋាន គ្រឿងបន្លាស់រថយន្ត និងសម្បកកង់។
គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២០ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មានក្រុមហ៊ុនកំពុងវិនិយោគនៅទីនោះសរុប ១៦៥៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ចេញផ្សាយនាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១។*

# តារាងប្រចាំសប្តាហ៍

## រូបភាព១៖ ការប៉ាន់ស្មានទ្រព្យសកម្មក្នុងវិស័យធនាគារបានកើនឡើង ក្នុងឆមាសទី១ ឆ្នាំ២០២១

យោងតាមរបាយការណ៍ប្រចាំឆមាសទី១នៃធនាគារជាតិនៃកម្ពុជា ទ្រព្យសកម្មក្នុងវិស័យធនាគារ ដែលមានដូចជាគ្រឹះស្ថានធនាគារពាណិជ្ជ និងធនាគារឯកទេស ត្រូវបានប៉ាន់ស្មានថា បានកើនឡើងក្នុងឆមាសទី១ ឆ្នាំ២០២១។

### ឥណទានគ្រឹះស្ថានធនាគារតាមវិស័យសេដ្ឋកិច្ច

(ឆមាសទី១ ឆ្នាំ២០២១ ប៉ាន់ស្មាន)




ទ្រព្យសកម្មក្នុងវិស័យធនាគារ បានកើនឡើង ១៨% ក្នុងទំហំទឹកប្រាក់កើនដល់ ២២២ ទ្រីលានរៀល ឬស្មើនឹង៥៥,១ ប៊ីលានដុល្លារអាមេរិក។ ឥណទានអតិថិជនកើនឡើង ១៩% ក្នុងទំហំទឹកប្រាក់កើនដល់ ១៣៧ ទ្រីលានរៀល ឬស្មើជិតនឹង៣៤ ប៊ីលានដុល្លារអាមេរិក ដោយបានផ្តល់ទៅកាន់វិស័យសេដ្ឋកិច្ចសំខាន់ៗ រួមមាន៖ ការជួញដូរដុំ និងរាយ (២៥%), ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិ (១៣%) និងសំណង់ (១០%)។ ទន្ទឹមនេះ ប្រាក់បញ្ញើបានកើនឡើង២១% ក្នុងទំហំទឹកប្រាក់១៣២ ទ្រីលានរៀល ឬ ស្មើនឹង ៣៣ ប៊ីលានដុល្លារអាមេរិក៕ ***ដោយ ឈន ហាំ***

*ប្រភព៖ របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ របស់ធនាគារជាតិ នៃកម្ពុជា ចុះថ្ងៃទី២២ ខែកក្កដា ២០២១*

## រូបភាព២៖ ការប៉ាន់ស្មានទ្រព្យសកម្មក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានកើនឡើង ក្នុងឆមាសទី១ ឆ្នាំ២០២១

យោងតាមរបាយការណ៍ប្រចាំឆមាសទី១ របស់ធនាគារជាតិនៃកម្ពុជា បានប៉ាន់ស្មានថា ទ្រព្យសកម្មក្នុងវិស័យគ្រឹះស្ថានហិរញ្ញវត្ថុដែលរួមមាន៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបានកើនឡើងក្នុងឆមាសទី១ ឆ្នាំ២០២១។

**ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញតាមវិស័យសេដ្ឋកិច្ច**

(ឆមាសទី១ ឆ្នាំ២០២១ ប៉ាន់ស្មាន)




ទ្រព្យសកម្មក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានកើនឡើង ១៤% ដែលកើនដល់ទំហំទឹកប្រាក់ ៣៦,២ ទ្រីលានរៀល ឬ ស្មើនឹង ៨,៩ ប៊ីលានដុល្លារអាមេរិក។ ឥណទានអតិថិជនបានកើនឡើង ១៩% ក្នុងទំហំទឹកប្រាក់ ៣០,៧ ទ្រីលានរៀល ឬស្មើនឹង៧,៦ ប៊ីលានដុល្លារអាមេរិក ដោយបានផ្តល់ទៅកាន់វិស័យសេដ្ឋកិច្ចសំខាន់ៗ រួមមាន៖ ក្រុមគ្រួសារ(២៨%), កសិកម្ម(២៥%) និងពាណិជ្ជកម្ម និងជំនួញ(២០%)។ ទន្ទឹមនេះ ប្រាក់បញ្ញើ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើង ១៩,៣% ដល់១៥,៧ ទ្រីលានរៀល ឬ ស្មើនឹង ៣,៩ ប៊ីលានដុល្លារអាមេរិក៕

***ដោយ ឈន ហាំ***

*ប្រភព៖ របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ របស់ធនាគារជាតិ នៃកម្ពុជា ចុះថ្ងៃទី២២ ខែកក្កដា ២០២១*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## កំណើនពាណិជ្ជកម្មរបស់វៀតណាម នៅក្នុងរយៈពេលពាក់កណ្តាលខែចុងក្រោយ ធៀបនឹងពាក់កណ្តាលដើមខែមិថុនា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

ស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់វៀតណាមមានចំនួន ១៤,៨៤ ពាន់លានដុល្លារ និងការនាំចូលមានចំនួន១៣,៩៤ ពាន់លានដុល្លារ ដែលនាំឱ្យមានអតិរេកពាណិជ្ជកម្មចំនួន ៨៩៤លានដុល្លារ ក្នុងរយៈពេលពាក់កណ្តាលខែចុងក្រោយនៃខែមិថុនា ឆ្នាំ២០២១ ។

បើប្រៀបធៀបទៅនឹងពាក់កណ្តាលដើមខែមិថុនា ឆ្នាំ ២០២១ ការនាំចេញកើនឡើង ២០,៦% ស្មើ ២,៥៣ ពាន់លានដុល្លារ។ ការកើនឡើងនេះ មានការរួមចំណែកពីកំណើនពីទូរស័ព្ទចល័ត និងគ្រឿងបន្លាស់ចំនួន ១១១,៤% ស្មើ ១,១៨ ពាន់លានដុល្លារ។ រីឯការនាំចេញដែក និងដែកថែបមានការកើនឡើងចំនួន ៦៥% ស្មើ ២២៨ លានដុល្លារ ហើយកុំព្យូទ័រ និងផលិតផលអគ្គិសនីកើនឡើងចំនួន ១០,៥% ស្មើ ២០៧ លានដុល្លារ។

ដោយឡែក ការនាំចូលបានកើនឡើង ២,១% ធៀបទៅនឹងពាក់កណ្តាលដើមខែ នៃខែមិថុនា ឆ្នាំ២០២១ ដែលនេះឆ្លុះបញ្ចាំងពីការកើនឡើងនៃការនាំចូលកំព្យូទ័រ គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់ ចំនួន ១០% ស្មើ ២៧៤ លានដុល្លារ។ ដោយឡែកការនាំចូលប្រេងឆៅកើនឡើង ១០៤% ស្មើ ១៤២ លានដុល្លារ ហើយដែក

និងដែកថែបកើនឡើង ១៩,៣% ស្មើ១០០ លានដុល្លារ។ *ដោយ ជឹម ប៊ុនធឿន*

| | ទំហំផ្លូវ | កំណើន (%) |
|---|---|---|
| **ការនាំចេញ** | ១៤,៨៤ | ២០,៦ |
| **ការនាំចេញ** | ១៣,៩៤ | ២,១ |
| **តុល្យភាពពាណិជ្ជកម្ម** | ០,៨៩ | - |

*ប្រភព៖ Vietnam Customs*

## កំណើននៃការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង របស់សិង្ហបុរី ទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែមិថុនា ឆ្នាំ២០២១

ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX: Non-oil domestic exports)) ទៅកាន់ទីផ្សារធំៗទាំង ១០ បានកើនឡើងនៅខែមិថុនា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

NODX ទៅកាន់ចិនបានកើនឡើង ២៧,៦% នៅក្នុងខែមិថុនា ឆ្នាំ២០២១ បន្ទាប់ពីមានកំណើន ៣៦,៩% នៅក្នុងខែឧសភា ឆ្នាំ២០២១។ ការកើនឡើងនេះ ដោយសារការនាំចេញម៉ាស៊ីនឯកទេសកើន ៤៨,៥% ឱសថកើន ១៨៩,៥% និងសារធាតុគីមីសំយោគពីប្រេង ឬឧស្ម័នធម្មជាតិ (petrochemicals) កើន ១២,៤%។ NODX ទៅកាន់សហគមន៍អឺរ៉ុបបានកើនឡើង ៣៦,៧% នៅក្នុងខែមិថុនា ឆ្នាំ២០២១ ដោយសារតែការនាំចេញម៉ាស៊ីនឯកទេសកើន ៣០៣,៥% ឱសថកើន១៧,៧% និងសារធាតុគីមីបឋម (primary chemicals) កើន ៤៣៧,១%។

NODX ទៅកាន់កោះតៃវ៉ាន់បានកើនឡើង ៤១,៤% នៅខែមិថុនាឆ្នាំ ២០២១ ខណៈការនាំចេញខែឧសភា កើនតែ ២៨,៦%។ កំណើននេះ ជំរុញដោយការនាំចេញ ICs មាន ៣៩,៤% ឧបករណ៍វាស់ស្ទង់ (measuring instruments) មាន៨៣,១% និងpetrochemicals មាន២២១,៥%។ ជារួម NODX ទៅកាន់ទីផ្សារធំៗទាំង១០ បានកើនឡើងនៅក្នុងខែមិថុនា ឆ្នាំ២០២១ ទោះបីជា NODX ទៅទីផ្សារអាមេរិក ជប៉ុន និងម៉ាឡេស៊ីបានធ្លាក់ចុះ។ ទីផ្សារធំបំផុត នៃ NODX របស់ប្រទេសសិង្ហបុរី គឺចិន (+២៧,៦%) សហភាពអឺរ៉ុប (+៣៦,៧%) និងតៃវ៉ាន់ (+៤១,៤%)។ *ដោយ ជឹម ប៊ុនធឿន*

| **ទីផ្សារធំៗ** | **កំណើននៃការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (%)** | |
|---|---|---|
| | ឧសភា ឆ្នាំ ២០២១ | មិថុនា ឆ្នាំ ២០២១ |
| **ចិន** | ៣៦,៩ | ២៧,៦ |
| **សហគមន៍អឺរ៉ុប** | -១,២ | ៣៦,៧ |
| **តៃវ៉ាន់** | ២៨,៦ | ៤១,៤ |
| **កូរ៉េខាងត្បូង** | ២០,៨ | ៤០,៩ |
| **ហុងកុង** | ៣០,២ | ៤៧,៧ |
| **ថៃ** | ២៤,៣ | ៤១,៥ |
| **ឥណ្ឌូនេស៊ី** | ៤២,៤ | ២៨,៨ |
| **ម៉ាឡេស៊ី** | ២៧,១ | -៥,៨ |
| **ជប៉ុន** | -២៣,៤ | -២២,៦ |
| **អាមេរិក** | -៣៥,៤ | -១០,៥ |

*ប្រភព៖www.enterprisesg.gov.sg*

## សេដ្ឋកិច្ចរបស់ថៃ កើនឡើងលើសពីការព្យាករណ៍ទុក នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១



*ប្រភព៖ Bangkok Post ២០២១ រូបភាព៖ Arnun Chonmhatrakool*

សេដ្ឋកិច្ចរបស់ថៃ បានកើនឡើងដោយមិននឹកស្មានដល់ នៅក្នុងត្រីមាសទី២ ពីត្រីមាសទី១ ឆ្នាំ២០២១ ដែលត្រូវបានជំរុញដោយការនាំចេញ និងការចំណាយរបស់រាជរដ្ឋាភិបាល បើទោះបីជាការផ្ទុះឡើងជាថ្មីនៃមេរោគឆ្លងកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ និងវិស័យទេសចរណ៍ក៏ដោយ។

យោងតាមទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ (NESDC) បានបង្ហាញថា កំណើនសេដ្ឋកិច្ចថៃ ផ្អែកតាមការកែសម្រួលតាមរដូវកាល បានកើនឡើងក្នុងអត្រា ០,៤% នៅក្នុងត្រីមាសទី២ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២១ ខណៈក្រុមអ្នកវិភាគដែលស្ទង់មតិដោយ Reuters បានព្យាករណ៍ថាធ្លាក់ចុះ -១,៤%។
ចំណែកឯ កំណើន ផ.ស.ស. នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ មានចំនួន ៧,៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារសេដ្ឋកិច្ចបានធ្លាក់ចុះយ៉ាងគំហុក នៅពេលដែលមេរោគរាតត្បាតកូវីដ-១៩ បានផ្ទុះឡើងជាលើកដំបូង។ អត្រានេះផងដែរ គឺលើសពីការព្យាករណ៍ដោយអ្នកសេដ្ឋកិច្ចដែលមានចំនួន៦,៤%។

ទោះយ៉ាងនេះក្តី រាជរដ្ឋាភិបាលថៃ បានកាត់បន្ថយការព្យាករណ៍កំណើនសេដ្ឋកិច្ចឆ្នាំ២០២១ របស់ខ្លួន មកត្រឹមរង្វង់ ០,៧-១,២% ធ្លាក់ចុះពីរង្វង់ ១,៥-២,៥% នៃការព្យាករណ៍លើកមុន ដោយសារការផ្ទុះឡើងជាថ្មីនៃមេរោគកូវីដ-១៩ និងវិធានការបិទខ្ទប់ ដែលបានរាំងសកម្មភាពក្នុងស្រុក ខណៈដំណើរការចាក់វ៉ាក់សាំងនៅទូទាំងប្រទេសមានភាពយឺតយ៉ាវ។
បច្ចុប្បន្ន NESDC រំពឹងថាការនាំចេញនឹងកើនឡើង ១៦,៣% នៅឆ្នាំ២០២១ នេះ ដែលកើនឡើងពី ១០,៣% នៃការព្យាករណ៍លើកមុន។
ចំណែកឯ ភ្ញៀវទេសចរបរទេសត្រូវបានព្យាករណ៍ថាមានចំនួន ០,១៥ លាននាក់ប៉ុណ្ណោះ នៅឆ្នាំនេះ ធ្លាក់ចុះពី ០,៥០លាននាក់នៃការព្យាករណ៍លើកមុន ខណៈភ្ញៀវបរទេសមានចំនួនប្រហែល ៤០លាននាក់ ក្នុងឆ្នាំ ២០១៩។
សូមបញ្ជាក់ដែរថា រាជរដ្ឋាភិបាលថៃ បានអនុម័តប្រាក់កម្ចីបន្ថែមទៀតចំនួន ៥០០ប៊ីលានបាត នៅឆ្នាំនេះ សម្រាប់វិធានការសង្គ្រោះបន្ទាន់៕ *ដោយ ស៊ិន សុភាព៍*

*ប្រភព៖ គេហទំព័រព័ត៌មាន Bangkok Post ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១*

## ប្រធានាធិបតីឥណ្ឌូនេស៊ី ជំរុញឱ្យមានការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ



*ប្រភព៖ Vietnam Plus ២០២១*

យោងតាមសុន្ទរកថារបស់លោកប្រធានាធិបតីឥណ្ឌូនេស៊ី Joko Widodo ដែលបានថ្លែងទៅកាន់ជនរួមជាតិ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ នេះ លោកសង្កត់ធ្ងន់ថា ជំងឺរាតត្បាតកូវីដ-១៩ ដែលបានអូសបន្លាយរយៈពេលមួយឆ្នាំកន្លះមកនេះ មិនអាចពន្យារពេលកំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិបានទៀតទេ។

លោកប្រធានាធិបតីបានមានប្រសាសន៍ថា រចនាសម្ព័ន្ធនៃសេដ្ឋកិច្ចឥណ្ឌូនេស៊ី (ដែលការប្រើប្រាស់របស់គ្រួសារបានរួមចំណែកច្រើនជាង ៥៥%) ត្រូវតែបន្តផ្លាស់ប្តូរឱ្យកាន់តែមានប្រសិទ្ធភាពតាមរយៈការជំរុញវិស័យឧស្សាហកម្ម ការវិនិយោគ និងការនាំចេញ។ លោកប្រធានាធិបតីក៏បានបញ្ជាក់ដែរថា ការវិនិយោគគឺជាសសរស្តម្ភដ៏សំខាន់មួយនៃសេដ្ឋកិច្ចជាតិ។ ក្នុងរយៈពេល ០៦ខែដំបូងនៃឆ្នាំ២០២១ នេះ ការចំណាយលើការវិនិយោគសរុបមានចំនួន ៤៤២,៨ទ្រីលានរូពៀ (ស្មើនឹង ៣០,៨ប៊ីលានដុល្លារអាមេរិក) ដោយមិនរាប់បញ្ចូលការរុករក និងការធ្វើអាជីវកម្មប្រេង និងឧស្ម័ន រួមទាំងសេវាកម្មហិរញ្ញវត្ថុ។

លោកបានសម្តែងក្តីសង្ឃឹមថា ការវិនិយោគសរុបនៅឆ្នាំ២០២១ នេះ នឹងឈានដល់គោលដៅ ៩០០ទ្រីលានរូពៀ ដែលរួមចំណែកក្នុងការបង្កើតការងារថ្មីៗជាច្រើន និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច។ រដ្ឋាភិបាលឥណ្ឌូនេស៊ីកំពុងផ្តោតលើការបង្កើតការងារថ្មីៗប្រកបដោយគុណភាពជាច្រើន ក្នុងកំឡុងពេលនៃការរាតត្បាតនៃជំងឺ-១៩។ វិធានការមួយក្នុងចំណោមវិធានការជាច្រើនលើការបង្កើតការងារថ្មីៗ គឺការពន្លឿនការអនុវត្តការផ្តល់អាជ្ញាបណ្ណអាជីវកម្មតាមច្រកចេញចូលតែមួយតាមប្រព័ន្ធអ៊ីនធឺណេត។

ទន្ទឹមនឹងនេះ លោកក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដោយផ្អែកលើនវានុវត្តន៍ និងបច្ចេកវិទ្យា ឆ្ពោះទៅរកសេដ្ឋកិច្ចបៃតង និងនិរន្តរភាព។ លោកបានបន្តបញ្ជាក់ថាសេដ្ឋកិច្ចបៃតងនឹងក្លាយជាការផ្លាស់ប្តូរដ៏សំខាន់នៃសេដ្ឋកិច្ចឥណ្ឌូនេស៊ី៕ *ដោយ ស៊ិន សុភាក៉*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Vietnam Plus ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២១*

## ពាណិជ្ជកម្មកម្ពុជា-ជប៉ុនកើនឡើងនៅឆមាសទី១ ឆ្នាំ ២០២១ ដល់ ១,១ ពាន់លានដុល្លារ



*ប្រភព៖ Chea Vanyuth, Khmer Times ២០២១*

ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជានិងជប៉ុន បានកើនឡើងនៅឆមាសទីមួយនៃឆ្នាំនេះ ដោយស្ទុះងើបឡើងវិញពីឆ្នាំមុនដែលត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារជំងឺកូវីដ១៩។

ទិន្នន័យពីអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) បានបង្ហាញថាចាប់ពីខែមករាដល់ខែមិថុនា កម្ពុជាបាននាំចេញផលិតផលចំនួន ៨១៤លានដុល្លារ ទៅប្រទេសជប៉ុន ដែលកើនឡើង ២,៧% និងបាននាំចូលទំនិញពីប្រទេសជប៉ុន ប្រមាណ ២៩៥ លានដុល្លារ កើនឡើង ៣៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

សរុបជារួម ទំហំពាណិជ្ជកម្មទ្វេភាគី មានតម្លៃ ១,១០៩ ពាន់លានដុល្លារ កើនឡើង ៩,៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ទន្ទឹមនឹងនេះ កំណើនពាណិជ្ជកម្មទ្វេភាគី បានបង្ហាញពីនិន្នាការវិជ្ជមាន បន្ទាប់ពីប្រទេសទាំងពីរ បានបង្ហាញពីលទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីផ្លូវការ។

ការនាំចេញសំខាន់ៗទៅកាន់ប្រទេសជប៉ុន រួមមានសម្លៀកបំពាក់ កាបូប ស្បែកជើង គ្រឿងសង្ហារឹម គ្រឿងសំអាង ក្រដាស និងសម្ភារៈការិយាល័យ រួមទាំងទំនិញស្បែក ខណៈដែលកម្ពុជា បាននាំចូលគ្រឿងម៉ាស៊ីន រថយន្ត គ្រឿងអេឡិចត្រូនិក គ្រឿងសង្ហារឹម ក្រណាត់ និងប្លាស្ទិក ពីប្រទេសជប៉ុន។

យោងតាមរបាយការណ៍ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឱ្យដឹងថា កម្ពុជា បាននាំចេញសរុប ចំនួន ៨,២០១ ពាន់លានដុល្លារ ក្នុងរយៈពេល ៦ ខែដំបូង នៃឆ្នាំ ២០២១ កើនឡើង ១៧% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ហើយប្រទេសជប៉ុនគឺជាទីផ្សារនាំចេញចម្បងមួយរបស់កម្ពុជា រួមទាំង សហរដ្ឋ-អាមេរិក សហភាពអឺរ៉ុប កាណាដា ចិន កូរ៉េខាងត្បូង និងសមាជិកអាស៊ាន។

*ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១*

## កម្ពុជា និងម៉ាឡេស៊ី មានប្រព័ន្ធទូទាត់ហិរញ្ញវត្ថុឌីជីថលឆ្លងដែន តាមរយៈកម្មវិធីទូទាត់ «បាគង»



*រូបថត៖ NBC*

កម្ពុជា និងម៉ាឡេស៊ី បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវការផ្ទេរប្រាក់តាមរយៈប្រព័ន្ធ "បាគង" របស់ធនាគារជាតិនៃកម្ពុជា (NBC) ជាមួយធនាគារ Maybank។ នេះ គឺជាចំណុចដ៏ល្អរវាងប្រទេសទាំង២ ក្នុងការជួយដល់ប្រជាជនក្នុងការផ្ទេរប្រាក់កាន់តែងាយស្រួល និងកាន់តែរហ័ស។

កិច្ចសហការគ្នានេះ ឆ្លើយតបនឹងការអភិវឌ្ឍបច្ចុប្បន្ននៃការទូទាត់ឆ្លងកាត់ព្រំដែន ដែលអាចជួយប្រជាជនកម្ពុជាដែលកំពុងធ្វើការងារនៅក្នុងប្រទេសម៉ាឡេស៊ី ក្នុងការផ្ញើប្រាក់ទៅគ្រួសាររបស់គេ ដោយការប្តូរពីរូបិយប័ណ្ណម៉ាឡេស៊ី ទៅជាប្រាក់រៀល។

ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា បានឱ្យដឹងថា កិច្ចសហការគ្នានេះ នឹងបង្កើនល្បឿនផ្ទេរប្រាក់រវាងពលរដ្ឋម៉ាឡេស៊ី និងកម្ពុជា។ ដូច្នេះ នៅពេលនេះគ្រប់គ្នាអាចផ្ទេរប្រាក់របស់ខ្លួន និងផ្ញើប្រាក់ទៅផ្ទះបានភ្លាមៗ និងងាយស្រួល។

លោកបញ្ជាក់ថា ភាពជាដៃគូរវាងធនាគារ Maybank Cambodia និង NBC បញ្ជាក់ពីកិច្ចសហប្រតិបត្តិការដ៏ល្អបំផុតរវាងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុនៃ

ប្រទេសទាំង២។ កិច្ចសហការគ្នានេះនឹងជួយបង្រួមគម្លាត និងការតភ្ជាប់រាល់ទំនាក់ទំនងទាំងអស់ឆ្ពោះទៅការពង្រឹងទំនាក់ទំនងទ្វេភាគីរបស់យើង និងបង្ហាញព្រឹត្តិការណ៍ដ៏សំខាន់ផ្សេងទៀតនៅក្នុងទំនាក់ទំនងរយៈពេល ៦៤ ឆ្នាំរបស់យើង ដែលរួមមានទំនាក់ទំនងផ្នែកនយោបាយ សេដ្ឋកិច្ច ការពារជាតិ ការអប់រំ និងវប្បធម៌។

អគ្គនាយិកាបច្ចេកទេសនៃNBCបានឱ្យដឹងថា កិច្ចសហការគ្នានេះ គឺគ្រាន់តែជាការចាប់ផ្តើមដំបូងប៉ុណ្ណោះ យើងនឹងមានការសហការជាមួយគ្នាជាច្រើនថែមទៀត ជាឧទាហរណ៍ នៅពេលនេះគឺជាការផ្ទេរប្រាក់តែម្ខាង ហើយយើងនឹងបន្តការងារការផ្ទេរប្រាក់ទាំងសងខាង ពោលគឺ ប្រជាជនមកពីប្រទេសម៉ាឡេស៊ីដែលរស់នៅក្នុងប្រទេសកម្ពុជា ក៏អាចផ្ញើប្រាក់ តាមរយៈ បាគង ទៅកម្មវិធីធនាគារ Maybank ទៅធនាគារក្នុងស្រុកនៅក្នុងប្រទេសម៉ាឡេស៊ីបានផងដែរ។

លោកស្រីក៏បានលើកឡើងដែរថា យើងក៏កំពុងស្វែងរកការទូទាត់តាម QR កូដ សម្រាប់ភ្ញៀវទេសចរ។ ដូច្នេះ ប្រព័ន្ធបាគង គឺដើម្បីធ្វើឱ្យការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកកាន់តែងាយស្រួល។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយនាថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០២១។*

## សេដ្ឋកិច្ចសកល

### និយោជកនៅចក្រភពអង់គ្លេស មានផែនការយ៉ាងមុតមាំក្នុងការជួលបុគ្គលិក ធៀបនឹងអំឡុងពេលជាង ៨ឆ្នាំ កន្លងមកនេះ




*ប្រភព៖Reuters ២០២១, រូបភាព៖ Phil Noble*

យោងតាមការស្ទង់មតិប្រចាំត្រីមាសដែលធ្វើឡើងដោយវិទ្យាស្ថានលក្ខន្តិកៈបុគ្គលិក និងការអភិវឌ្ឍន៍ (CIPD) របស់ចក្រភពអង់គ្លេស បានបង្ហាញថា និយោជកនៅចក្រភពអង់គ្លេសជាច្រើនមានគម្រោងបង្កើនចំនួនបុគ្គលិកឱ្យបានច្រើនបំផុតនៅប៉ុន្មានខែខាងមុខនេះ ធៀបនឹងរយៈពេលជាង៨ឆ្នាំកន្លងមក ខណៈ មាននិយោជកចំនួនតិចតួចប៉ុណ្ណោះ ដែលមានបំណងបញ្ឈប់បុគ្គលិកពីការងារ នៅពេលដែលគម្រោងគាំទ្ររបស់រដ្ឋាភិបាលនឹងបញ្ចប់នៅខែក្រោយនេះ។

CIPD បានបញ្ជាក់ដែរថា មានសញ្ញានៃកង្វះទីផ្សារការងារនៅពេលដែលសេដ្ឋកិច្ចចាប់ផ្តើមងើបឡើងវិញពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ជាពិសេសនៅក្នុងវិស័យបដិសណ្ឋារកិច្ច ដោយមូលហេតុនិយោជកជាច្រើនបានបញ្ឈប់បុគ្គលិកកំឡុងពេលនៃការរាតត្បាតពីជំងឺ

ដោយសារការបិទសណ្ឋាគារ ហាងស្រា ភោជនីយដ្ឋាន និងកន្លែងផ្សេងៗទៀត។ ទោះយ៉ាងណា មានភស្តុតាងតិចតួចប៉ុណ្ណោះដែលបង្ហាញអំពីសម្ពាធប្រាក់ឈ្នួល ឬអតិផរណា។

ការស្ទង់មតិបានបង្ហាញថា សមតុល្យនៃការងារសរុប ដែលជាភាពខុសគ្នានៃពិន្ទុភាគរយ រវាងការជួលបុគ្គលិក និងការបញ្ឈប់បុគ្គលិក បានកើនឡើងពី +២៧ ទៅ +៣២ ក្នុងរយៈពេល ៣ខែចុងក្រោយនេះ ដែលជាតួលេខខ្ពស់បំផុតចាប់តាំងពីការស្ទង់មតិចាប់ផ្តើមនៅក្នុងឆ្នាំ២០១៣។ និយោជកមានសុទិដ្ឋិនិយមខ្ពស់ចំពោះការជ្រើសរើសបុគ្គលិកច្រើន ខណៈ ដែលការរំពឹងទុកនៃការបញ្ឈប់បុគ្គលិកមានកម្រិតទាប ជាងការព្យាករណ៍ដំបូង ក្នុងអំឡុងពេលមានការរីករាលដាលជំងឺកូវីដ-១៩។ ក្នុងនោះមានតែនិយោជកចំនួន ១៣%ប៉ុណ្ណោះដែលមានគម្រោងបញ្ឈប់បុគ្គលិក ធ្លាក់ចុះពី ៣៣% ពីឆ្នាំ២០២០ ដោយសារមានការភ័យខ្លាចពីការបញ្ចប់ការគាំទ្ររបស់រដ្ឋាភិបាល ដែលអាចនឹងបណ្តាលឱ្យមានការកើនឡើងនូវនិកម្មភាព។

ទន្ទឹមនឹងនេះ និយោជក បានតម្លើងប្រាក់ឈ្នួលប្រចាំឆ្នាំជាមធ្យមចំនួន ២% ដល់បុគ្គលិកនៅរដូវក្តៅនេះ ដោយមិនមានការផ្លាស់ប្តូរពីនិទាឃរដូវ និងស្រប តាមបទដ្ឋានមុនពេលមានជំងឺរាតត្បាត។

ទោះជាយ៉ាងណា ការតម្លើងប្រាក់ឈ្នួលក៏មិនត្រូវបានគេមើលឃើញថាជាដំណោះស្រាយចំពោះកង្វះបុគ្គលិកដែរ។ និយោជកចំនួន ២៣% ប៉ុណ្ណោះដែលពិបាកក្នុងការជ្រើសរើសបុគ្គលិកមកបំពេញមុខតំណែងទំនេរ ហើយពួកគេបាននិយាយថាពួកគេនឹងតម្លើងប្រាក់ឈ្នួល ខណៈដែល ៤៤% នៃនិយោជកមានបំណង បណ្តុះបណ្តាល បុគ្គលិកដែលមានស្រាប់ដើម្បីបំពេញមុខតំណែងទំនេរទាំងនោះ។

ដោយឡែក យោងតាមការព្យាករណ៍របស់ធនាគារអង់គ្លេសដែលធ្វើឡើងកាលពីដើមខែសីហានេះ បានបង្ហាញថាអត្រានិកម្មភាពនឹងមិនកើនឡើងលើសពី ៤,៨% ដែលទាបជាងការព្យាករណ៍កាលពីមុនក្នុងអត្រា ប្រមាណ ៧,៥% ។ *ដោយ សេន ចន្ទី*

*ប្រភព៖ Reuters ចេញផ្សាយថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១*

## រដ្ឋបាលលោកប្រធានាធិបតី បៃដិន បញ្ជាក់ពីការបង្កើនបណ្ណសម្រាប់ទិញអាហារ ក្នុងកំណត់ត្រាឯកត្តកម្ម




*ប្រភព៖ Reuters ២០២១, រូបភាព៖ Patrick T.Fallon*

ក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (USDA)បានធ្វើការប្រកាសអំពីការកែសម្រួលស្តង់ដារអាហារូបត្ថម្ភ ដែលនឹងបង្កើនអត្ថប្រយោជន៍យ៉ាងច្រើននៃបណ្ណសម្រាប់ទិញអាហារជាមធ្យម។

កម្មវិធីនេះ បានបង្ហាញពីផែនការក្នុងការបង្កើនអត្ថ-ប្រយោជន៍ អចិន្ត្រៃយ៍ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃកម្មវិធីប្រឆាំងភាពអត់ឃ្លានដ៏សំខាន់បំផុតរបស់រដ្ឋាភិបាល ដោយការផ្លាស់ប្តូរនេះនឹងបង្កើននូវអត្ថប្រយោជន៍ជា

មធ្យមជាង ២៥% ធៀបនឹងកម្រិតមុនពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩។

យោងតាមវិធានថ្មីនេះ គិតចាប់ពីខែតុលា ឆ្នាំ២០២១ អត្ថប្រយោជន៍ប្រចាំខែជាមធ្យមនឹងកើនឡើង ៣៦ ដុល្លារអាមេរិក បន្ថែមពីលើ ១២១ ដុល្លារអាមេរិក សម្រាប់មនុស្សម្នាក់ នៃចំនួនមុនពេលការរាតត្បាត ដែលប្រជាពលរដ្ឋ ចំនួន ៤២លាននាក់ នៅក្នុងកម្មវិធីនេះនឹងទទួលបានជំនួយបន្ថែម។

ស្របពេលជាមួយគ្នានេះ ការបង្កើនអត្ថប្រយោជន៍បណ្តោះអាសន្នចំនួន ១៥% ដែលជាផ្នែកមួយនៃការជួយសង្គ្រោះពីការរាតត្បាតនៃជំងឺកូវីដ-១៩ នឹងផុតកំណត់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។ កញ្ចប់ថវិកាជំរុញចំនួន ៣,៥ប៊ីលានដុល្លារអាមេរិក ដែលបានអនុម័តនៅដើមឆ្នាំនេះ នឹងផ្តល់ប្រាក់ប្រហែល ២៧ដុល្លារអាមេរិក បន្ថែមទៀតសម្រាប់មនុស្សម្នាក់ក្នុងមួយខែ ឬលើសពី ១០០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់មួយគ្រួសារដែលមានសមាជិកបួននាក់ នៅក្នុងអត្ថប្រយោជន៍បន្ថែមនៃបណ្ណសម្រាប់ទិញអាហារ។

សូមបញ្ជាក់ដែរថា ផែនការថ្មីនេះ នឹងបង្កើនការចំណាយចំនួន ៧៩ប៊ីលានដុល្លារអាមេរិកនៃកម្មវិធីប្រចាំឆ្នាំ កើនឡើងប្រហែល ២០ប៊ីលានដុល្លារអាមេរិក ធៀបនឹងកម្រិតមុនពេលនៃការរាតត្បាត។ នៅឆ្នាំ២០១៩ មានប្រជាជនប្រហែល ១១% នៃប្រជាជនអាមេរិក ប៉ុណ្ណោះដែលបានអត្ថប្រយោជន៍ពីកម្មវិធីនេះ៕ *ដោយ សេន ចន្ទី*

*ប្រភព៖ Reuters ចេញផ្សាយថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១*

## សេដ្ឋកិច្ចរុស្ស៊ីងើបឡើងវិញក្នុងត្រីមាសទី ២ ដោយកត្តាជំរុញសំខាន់ ៣



*ប្រភព ៖ AFP*

សេដ្ឋកិច្ចប្រទេសរុស្ស៊ីស្ទុះងើបឡើងវិញនៅក្នុងត្រីមាសទី២ ពេលដែលប្រទេសនេះងើបផុតពីផលប៉ះពាល់នៃការរីករាលដាលវីរុសកូរ៉ូណា។
ផលិតផលក្នុងស្រុកសរុបកើនឡើង ១០,៣% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ កំណើនខ្លាំង គឺទទួលបានពីការដឹកជញ្ជូនអ្នកដំណើរ ពាណិជ្ជកម្មលក់រាយ និងការជីករ៉ែ។

សេដ្ឋកិច្ចរបស់ប្រទេសរុស្ស៊ី បានធ្លាក់ចុះក្នុងត្រីមាសដំបូងនៃឆ្នាំ២០២១នេះ។ ប្រទេសរុស្ស៊ីបានដាក់ការបិទខ្ទប់ប្រទេសតែម្តងគត់កាលពីនិទាឃរដូវឆ្នាំមុន បានធ្វើឱ្យសេដ្ឋកិច្ចធ្លាក់ចុះដល់ទៅ ៣,១% តែនៅប្រសើរជាងប្រទេសខ្លះនៅតំបន់អឺរ៉ុប ដែលបានដាក់ការបិទខ្ទប់ញឹកញាប់ និងមានរយៈពេលវែងជាង ហើយរុស្ស៊ីបន្តបើកសេដ្ឋកិច្ចរហូតចាប់តាំងពីពេលនោះមកដែរ។ ប៉ុន្តែប្រទេសរុស្ស៊ី គឺដូចជាប្រទេសជាច្រើនទៀតដែរ កំពុងប្រឈមនឹងកំណើនអត្រាអតិផរណា ដែលជាការបារម្ភនៅមុនការបោះឆ្នោតសភាក្នុងខែកញ្ញាខាងមុខនេះ៕
*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១។*

## ការប្រើប្រាស់មាសនៅចិនកើនឡើងជាង ៦៩% ក្នុងឆមាសទី១ឆ្នាំនេះ



*ប្រភព ៖ cnc*

ការប្រើប្រាស់មាសនៅក្នុងប្រទេសចិនបានកើនឡើង ៦៩,២១%នៅក្នុងឆមាសទី១ឆ្នាំនេះ បើធៀបទៅនឹងឆ្នាំមុន។ មូលហេតុសំខាន់នៃការកើនឡើងនេះ គឺការចំណាយប្រើប្រាស់របស់ពលរដ្ឋក្នុងថ្ងៃឈប់សម្រាកជាបន្តបន្ទាប់ដូចជាទិវាពលកម្ម និងពិធីបុណ្យអុំទូកនាគ។

ទិន្នន័យរបស់សមាគមមាសចិនបានបង្ហាញថា ការប្រើប្រាស់កាក់មាស និងមាសដុំបានកើនឡើង៩៦,២៨% បើធៀបទៅនឹងឆមាសទី១ក្នុងឆ្នាំ២០២០ ខណៈដែលការប្រើប្រាស់មាសសម្រាប់វិស័យឧស្សាហកម្ម និងការប្រើប្រាស់ផ្សេងទៀតបានកើនឡើង២៣,២៨%។ ការប្រើប្រាស់មាសសម្រាប់ផលិតគ្រឿងអលង្ការនៅក្នុងទីផ្សារចិនបានកើនឡើង៦៧,៦៨%ក្នុងចន្លោះពីខែមករាដល់ខែមិថុនាឆ្នាំនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cnc ចេញផ្សាយថ្ងៃទី ១២-សីហា-២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៣ ខែសីហា ឆ្នាំ២០២១

- កំណើនខ្ពស់បំផុតនៃជនបរទេស មកលេងប្រទេសទួរគីបានកើនឡើង នៅក្នុងខែមិថុនាឆ្នា២០២១
- កំណើននៃការលក់រាយនៅម៉ិកស៊ិក បានកើនឡើង ០,៦០%នៅខែឧសភាឆ្នាំ ២០២១ ធៀបនឹងខែមុន

ថ្ងៃអង្គារ ទី២៤ ខែសីហា ឆ្នាំ២០២១

- កំណើនសេដ្ឋកិច្ចអាល្លឺម៉ង់ ១,៥ %នៅត្រីមាសទី៣ ឆ្នាំ ២០២១
- ការផលិតរថយន្តនៅក្នុងប្រទេសទួរគីបានកើនឡើង ៣,៨ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំដល់ ១០៧២១៩ គ្រឿងក្នុងខែមិថុនាឆ្នាំ ២០២១ ។

ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ២០២១

- កំណើននៃការលក់រាយនៅអាហ្សង់ទីន បានកើនឡើង ៧២៩% នៅខែឧសភាឆ្នាំ ២០២១
- ចំនួនមនុស្សដែលបានចុះឈ្មោះចេញពីការងារនៅប្រទេសចិនដីគោកបានធ្លាក់ចុះ

ថ្ងៃព្រហស្បតិ៍ ទី២៦ ខែសីហា ឆ្នាំ២០២១

- កំណើនការវិនិយោគភាគហ៊ុន ដោយជនបរទេសនៅក្នុងប្រទេសជប៉ុន កើនឡើង ១០៤,៩០ ពាន់លានយ៉េនក្នុងសប្តាហ៍ដែលបញ្ចប់នៅថ្ងៃទី ៧ ខែសីហាឆ្នាំ ២០២១
- កំណើនចំណាយមូលធនថ្មីសរុប នៅអូស្ត្រាលីក្នុងមួយត្រីមាសនៅត្រីមាសទី៣ ឆ្នាំ២០២១

ថ្ងៃសុក្រ ទី២៧ ខែសីហា ឆ្នាំ២០២១

- កំណើនតម្លៃប្រាក់កម្ចី នៅប្រទេសឥណ្ឌូនេស៊ី នៅក្នុងខែមិថុនាឆ្នាំ ២០២១ ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន
- អតិរេកពាណិជ្ជកម្មរបស់ម៉ិកស៊ិក បានធ្លាក់ចុះយ៉ាងខ្លាំង នៅខែមិថុនាឆ្នាំ២០២១៕